**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលនិងការដំឡើងប្រាក់បំណាច់មុខងារ ជូនមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២០២ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់សមមូលឋានន្តរស័ក្តិមន្ត្រីពន្ធនាគារជាមួយនឹងឋានន្តរស័ក្តិមន្ត្រីរាជការស៊ីវិលនិងមន្ត្រីនគរបាលជាតិ និងការធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

### មាត្រា១ .-

អនុក្រឹត្យនេះមានគោលបំណងកែសម្រួលនិងដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ដើម្បីធានាបាននូវសមធម៌ សង្គតិភាព ប្រសិទ្ធភាព និងការបង្កើនផលិតភាពការងារ។

### មាត្រា២ .-

អនុក្រឹត្យនេះមានគោលដៅរៀបចំកែសម្រួលនិងដំឡើងប្រាក់បំណាច់មុខងាររបស់មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ។

**មាត្រា៤ .-**

ប្រាក់បំណាច់មុខងាររបស់មន្ត្រីពន្ធនាគារ ត្រូវបានរៀបចំបែងចែកតាមលំដាប់នៃមុខតំណែង ដូចមានក្នុងតារាងខាងក្រោម ៖

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | អគ្គនាយក | ១ ៧៥០ ០០០ |
| ២ | អគ្គនាយករង | ១ ៤០០ ០០០ |
| ៣ | ប្រធាននាយកដ្ឋាន | ៧០០ ០០០ |
| ៤ | អនុប្រធាននាយកដ្ឋាន<br>ប្រធានមណ្ឌលអប់រំកែប្រែ<br>ប្រធានពន្ធនាគាររាជធានី ខេត្ត | ៦០០ ០០០ |
| ៥ | ប្រធានការិយាល័យថ្នាក់កណ្ដាល<br>អនុប្រធានមណ្ឌលអប់រំកែប្រែ<br>អនុប្រធានពន្ធនាគាររាជធានី ខេត្ត | ៤២០ ០០០ |
| ៦ | អនុប្រធានការិយាល័យថ្នាក់កណ្ដាល<br>ប្រធានការិយាល័យមណ្ឌលអប់រំកែប្រែ<br>ប្រធានការិយាល័យពន្ធនាគាររាជធានី ខេត្ត | ៣១០ ០០០ |
| ៧ | ប្រធានផ្នែកថ្នាក់កណ្ដាល<br>អនុប្រធានការិយាល័យមណ្ឌលអប់រំកែប្រែ<br>អនុប្រធានការិយាល័យពន្ធនាគាររាជធានី ខេត្ត | ២៥០ ០០០ |
| ៨ | អនុប្រធានផ្នែកថ្នាក់កណ្ដាល<br>ប្រធានផ្នែកមណ្ឌលអប់រំកែប្រែ<br>ប្រធានផ្នែកពន្ធនាគាររាជធានី ខេត្ត | ២១០ ០០០ |
| ៩ | នាយត្រួតថ្នាក់កណ្ដាល<br>អនុប្រធានផ្នែកមណ្ឌលអប់រំកែប្រែ<br>អនុប្រធានផ្នែកពន្ធនាគាររាជធានី ខេត្ត | ១៩០ ០០០ |
| ១០ | នាយត្រួតរងថ្នាក់កណ្ដាល<br>ប្រធានក្រុមមណ្ឌលអប់រំកែប្រែ<br>ប្រធានក្រុមពន្ធនាគាររាជរាជធានី ខេត្ត | ១៨៥ ០០០ |
| ១១ | អនុប្រធានក្រុមមណ្ឌលអប់រំកែប្រែ<br>អនុប្រធានក្រុមពន្ធនាគាររាជធានី ខេត្ត | ១៨០ ០០០ |
| ១២ | មន្ត្រីពន្ធនាគារ | ១៥០ ០០០ |

ប្រាក់បំណាច់មុខងារខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦តទៅ។

**មាត្រា៥ .-**

ក្នុងករណីប្រាក់បំណាច់មុខងាររបស់មន្ត្រីពន្ធនាគារដែលមានកំណត់ក្នុងមាត្រា៤នៃអនុក្រឹត្យនេះ ទាបជាងប្រាក់បំណាច់មុខងាររបស់មន្ត្រីពន្ធនាគារដែលកំពុងទទួលបានបច្ចុប្បន្ន ប្រាក់បង្គ្រប់នឹងត្រូវអនុវត្តបន្ថែមលើប្រាក់បំណាច់មុខងារឱ្យមានចំនួនស្មើនឹងប្រាក់បំណាច់មុខងាររបស់មន្ត្រីពន្ធនាគារដែលកំពុងទទួលបានបច្ចុប្បន្ន។

**មាត្រា៦ .-**

មន្ត្រីពន្ធនាគារដែលកំពុងស្ថិតក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងតំណែងនោះ។ ករណីមន្ត្រីពន្ធនាគារដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតឱ្យជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយគត់។

**មាត្រា៧ .-**

ការកែប្រែចំនួនមុខតំណែងឬប្រាក់បំណាច់មុខងារដូចមានចែងក្នុងមាត្រា៤ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ .-**

មន្ត្រីពន្ធនាគារដែលមានសិទ្ធិទទួលប្រាក់បំណាច់មុខងារ ត្រូវស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

- កំពុងបំពេញកម្មសិក្សាវិជ្ជាជីវៈឬបច្ចេកទេសតាមតម្រូវការរបស់រដ្ឋ
- កំពុងបំពេញកម្មសិក្សាជាដំបូងដើម្បីតាំងស៊ប់ក្នុងក្របខណ្ឌ
- កំពុងបំពេញការងារក្នុងក្របខណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- កំពុងផ្លាស់ប្តូរកន្លែងធ្វើការនិងកំពុងធ្វើដំណើរទៅកាន់មុខតំណែងនៅក្នុងឬក្រៅប្រទេស
- កំពុងបំពេញការសិក្សាក្នុងឬក្រៅប្រទេសតាមតម្រូវការរបស់ក្របខណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃពលី មរណៈ ពិការ និវត្តជន បាត់បង់សមត្ថភាពការងារដែលមិនទាន់ផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្ត
- មន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃដែលទទួលការអនុញ្ញាតច្បាប់ក្នុងធុរៈផ្ទាល់ រយៈពេលសម្រាកព្យាបាលជម្ងឺនិងបាត់ខ្លួនក្នុងបេសកកម្ម។

**មាត្រា៩ .-**

ការបញ្ឈប់ការបើកផ្តល់ប្រាក់បំណាច់មុខងារ ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងករណីដូចខាងក្រោម៖

- មន្ត្រីពន្ធនាគារសុំលាឈប់ពីការងារដោយមានការអនុញ្ញាត
- មន្ត្រីពន្ធនាគារដែលត្រូវបានដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស
- មន្ត្រីពន្ធនាគារដែលមានប្រកាសបណ្តេញចេញពីក្របខណ្ឌមន្ត្រីពន្ធនាគារ
- មន្ត្រីពន្ធនាគារដែលអវត្តមានគ្មានការអនុញ្ញាតឬហួសកំណត់ដោយសម្អាងលើប្រធានស័ក្តិដែលមិនសមស្រប
- មន្ត្រីពន្ធនាគារពលី មរណៈ ពិការ និវត្តជន បាត់បង់សមត្ថភាពការងារដែលបានផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្តរួចហើយ
- មន្ត្រីពន្ធនាគារដែលបាត់បង់ឋានន្តរស័ក្តិតាមសាលក្រមឬសាលដីកាស្ថាពររបស់តុលាការ។

**មាត្រា១០ .-**

របបឧបត្ថម្ភផ្សេងៗទៀតក្រៅពីប្រាក់បំណាច់មុខងារ ត្រូវបន្តអនុវត្តជាធរមានរហូតដល់មានការកែប្រែជាថ្មី។

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ